ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍

# ស្តីពី

# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ប្រចាំឆមាសទី១ ឆ្នាំ២០១៣

## I- សភាពការណ៍រួម

ក្នុងឆមាសទី១ ឆ្នាំ២០១៣នេះ ស្ថានភាពអាកាសធាតុទទួលឥទ្ធិពលពីខ្យល់មូសុងរួមជាមួយនឹងខ្យល់កន្ត្រាក់បក់មកពីទិសនិរតី ផ្តែមេឃមានភ្លៀងធ្លាក់ជាមធ្យមនិងច្រើននៅតាមតំបន់មួយចំនួននៃរាជធានី ខេត្ត។ ទោះបីទឹកភ្លៀងមិនទាន់អំណោយផលល្អប្រសើរគ្រប់តំបន់យ៉ាងណាក៏ដោយ ក៏ប្រជាកសិករទូទាំងប្រទេសបាននិងកំពុងខិតខំជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការងារបង្កបង្កើនផលស្រូវមានជាអាទិ៍ ការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ ដក-ស្ទូង ស្មើនឹង២៨,០៧ភាគរយ នៃផែនការដាំដុះ ២.៣៩៩.៦៣៧ហិកតា។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

##### ១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន១.២៧៥.០០១ហិកតា (ក្នុងនោះគោ-ក្របីចំនួន២៣៥.១៨៤ហិកតា) តិចជាងឆ្នាំមុន ២១៤.៣២៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ២១៦.៣១៦ហិកតា

-ផ្ទៃដីសាបសរុបចំនួន៥២.១១៧ហិកតា តិចជាងឆ្នាំមុន៣៣.៧៨៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៧៥.៣១១ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៦៧៣.៦៤៩ហិកតា ស្មើនឹង២៨,០៧% នៃផែនការ២.៣៩៩.៦៣៧ហិកតា តិចជាងឆ្នាំមុន១៨៣.៣៧៩ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ១៥៤.៩៣៦ហិកតា

- ស្រូវស្រាលចំនួន ២៥៤.៦៤១ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៨២.៦០៤ហិកតា) តិចជាងឆ្នាំមុន ៦៣.៣៩៤ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំ ៣៣.៧៩៦ហិកតា
- ស្រូវកណ្តាលចំនួន ១៧៤.៧៨១ហិកតា តិចជាងឆ្នាំមុន ៧៥.៥៣៨ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៨១.៥៨៩ហិកតា
- ស្រូវធ្ងន់ចំនួន ១៤៩.៨៧០ហិកតា តិចជាងឆ្នាំមុន ៤១.២៣៩ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៦៦.២៨៤ហិកតា
- ស្រូវចម្ការចំនួន ៣៦.០២៤ហិកតា លើសឆ្នាំមុន ៧៧៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៦.៥២៧ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak Khan Chamkarmon Phnom Penh Cambodia
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 726 129 Fax: (855) 23 217 320

• ស្រូវឡើងទឹកចំនួន ៥៨.៣៣៣ហិកតា តិចជាងឆ្នាំមុន ៣.៩៨១ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំ ៣៤.៣៣២ហិកតា។

១.១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន ៤៦៩.៤៤២ហិកតា ស្មើនឹង ៩០,៧៦ភាគរយ នៃផែនការសរុប ៥១៧.២៦០ហិកតា លើសឆ្នាំមុន ៨១.០៦៦ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីដាំពោតចំនួន៩៨.០៧៩ហិកតា លើសឆ្នាំមុន១៨.៣៩៥ហិកតា ក្នុងនោះផ្ទៃដីដាំពោតក្រហមមាន៨៧.៧៨០ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន ៣១១.០០៣ហិកតា លើសឆ្នាំមុន ៦៥.៧២៤ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន ២.៩៩៨ហិកតា លើសឆ្នាំមុន ១០៦ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន ១៨.៦១៦ហិកតា តិចជាងឆ្នាំមុន ២.៥៨៦ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន ៣៨.៧៤៦ហិកតា តិចជាងឆ្នាំមុន ៥៧៣ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន ៥៩.២២៩ហិកតា ស្មើនឹង ៣៨,៣៥ភាគរយ នៃផែនការសរុប ១៥៤.៤២៩ហិកតា តិចជាងឆ្នាំមុន ៧.៧៨៣ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីសណ្តែកដីចំនួន ១៣.៣០១ហិកតា លើសឆ្នាំមុន ២.០៣១ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន ១.៥៣៤ហិកតា លើសឆ្នាំមុន ១.២៥៦ហិកតា

-ផ្ទៃដីល្ងចំនួន ២៩.០៣៧ហិកតា តិចជាងឆ្នាំមុន ១៦.០៤២ហិកតា

-ផ្ទៃដីអំពៅចំនួន ១៥.០៦០ហិកតា លើសឆ្នាំមុន ៤.៨៨៦ហិកតា

-ផ្ទៃដីក្រចៅចំនួន ២១៦ហិកតា លើសឆ្នាំមុន ៣៦ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ៨១ហិកតា លើសឆ្នាំមុន ៥០ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិ សរុបចំនួន២៩.៣២០.២៩៤.៨៨៤រៀល ដែលក្នុងនោះបានមកពីចំណូលថ្លៃសួយសារផល អនុផលព្រៃឈើចំនួន២៤.២៤០.៤០០.០៩៨រៀល ផលទុនពីការលក់-ផ្ទួលទ្រព្យសម្បត្តិនិងសេវាចំនួន ៨.៨០០.០០០រៀល និងចំណូលបានពីការផាកពិន័យឈើដែលបានមកពីការបង្ក្រាបបទល្មើសចំនួន៥.០៧១.០៩៤.៧៨៦រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើចំនួន១២ស្ថានីយ គឺស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើអង្គាញ់ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើស្រែណូយ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើឃុនរាម ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើឆែប ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើកូនក្រៀល ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើត្រពាំងតាវ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើកូនខ្លែង ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើរមនា ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើសែនមនោរម្យ ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើក្រយា-បឹងល្វា ស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើទីវែង និងស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើសណ្តាន់

-ផ្ញើសារលើកវត្ថុវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន២០

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ចេញពីព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន÷ ឈើហ៊ុបមូលសរុបចំនួន ៩០.៣៧៤,៥២៤ម៣ ឈើអារចំនួន ៥៩៩,៦០២ម៣ ឈើជ្រុងចំនួន ៦.២៤៦,៨៥៦ម៣ ឈើកែច្នៃ (S2S,S4S) ចំនួន ១០០,០០២ម៣ កូនឈើចំនួន ៦០៦.២១០ដើម អុសចម្រុះចំនួន ១២៨.៧៦៤ស្ទែរ ជ័រទឹកនិងជ័រស្ងួតចំនួន

៦៤០,៩២៤តោន បង្គោងឫស្សីចំនួន ៩០តោន សសរចំនួន ៨៨ដើម និងវល្លិ៍រមៀតចំនួន ១.០០០.១៦៨គីឡូក្រាម។

## ២.៣ ការងារអភិរក្សសត្វព្រៃ

-កត់ត្រាក្រុមប្រភេទសត្វស្លាបជិតផុតពូជ ក្រុមមានដោយកម្រ និងក្រុមមានដោយបង្ខួរតាមបណ្តាព្រៃការពារនៅក្នុងតំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម តំបន់អភិរក្សបឹងព្រែកល្ពៅ តំបន់អភិរក្សអន្លង់ព្រីង តំបន់អភិរក្សសត្វខ្សឹប និងតំបន់ព្រៃការពារមណ្ឌលគីរី

-កត់ត្រាកូនក្រពើទាំងអស់ចំនួន៣៣ក្បាលដែលយកមកពីក្នុងព្រៃធម្មជាតិនៅតំបន់ស្ទឹងអារ៉ែង និងកំពុងចិញ្ចឹមបំប៉នដើម្បីរង់ចាំការលែងក្នុងតំបន់សុវត្ថិភាព

-កេឃើញសម្បុកត្រដក់ត្អូចចំនួន៣២សម្បុក ត្រយ៉ងចង្កំកសចំនួន៦៨សម្បុក ត្មាតភ្លើងចំនួន០១សម្បុក ត្មាតផេះចំនួន០៩សម្បុក ត្មាតត្នោតចំនួន០៧សម្បុក រំពេទន្លេចំនួន១០សម្បុក និងកន្ទាយក្បាលកង្កែបចំនួន៧៩សម្បុក ក្នុងតំបន់ការពារសម្បុកសត្វក្នុងខេត្តក្រចេះនិងខេត្តស្ទឹងត្រែង ក្នុងតំបន់សៀងប៉ាងភាគខាងលិច និងតំបន់ព្រៃការពារមណ្ឌលគីរី

-ដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន៥៤គ្រឿងនៅក្នុងតំបន់ព្រៃការពារព្រះវិហារ និង១៥គ្រឿងនៅក្នុងតំបន់សៀមប៉ាងខេត្តស្ទឹងត្រែង និង២៣គ្រឿងនៅក្នុងតំបន់ព្រៃការពារមណ្ឌលគីរី និង២៥គ្រឿងនៅក្នុងតំបន់ជួរភ្នំក្រវាញផ្នែកខាងលិចលើភ្នំ ដើម្បីសិក្សាពីរបាយនិងការបន្លាស់ទីរបស់សត្វគ្រប់ប្រភេទជាពិសេសដំរីព្រៃ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំសត្វចំណូលថ្មីចំនួន៣២០ក្បាល សត្វកើតថ្មីចំនួន១៥ក្បាល សត្វដោះលែងចំនួន១៣៣ក្បាល សត្វស្លាប់ចំនួន៦៦ក្បាល ព្យាបាលសត្វចំនួន១៤៨ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៥២ក្បាល ធ្វើឲ្យសន្លប់ចំនួន៨៤ក្បាល ទម្លាក់សត្វល្អិតចំនួន១៩៨ក្បាល វះកាត់សាកសពសត្វចំនួន២៣ក្បាល ដាក់លេខកូដចំនួន០៩ក្បាល ចាក់វ៉ាក់សាំងចំនួន២៩៣ក្បាល ជួសជុលផ្លូវចំនួន១៦០,១៧៧ម$^2$ និងភ្លារអនាម័យព្រៃ៦៧.០៧៩ម$^2$ សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៣.៥៦១ម$^2$ សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១២.០១៨ម$^2$ សាងសង់សំណង់ផ្សេងៗចំនួន៩៧៥ម$^2$ ដាំកូនឈើចំនួន២៥១ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៣.២០៨ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៦.០៤៣នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៧៦.៧៣៨ក្បាល។

## ២.៤ ការងារដាំដើមឈើ

-ស្រាវជ្រាវពូជឈើដូនចែមដើម្បីអភិរក្សក្នុងតំបន់នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ និងចម្ការពូជឈើទាលទឹកនៅស្ថានីយក្បាលឆាយទំហំ៥ហិកតា ដើម្បីអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៥របស់រដ្ឋបាលព្រៃឈើ÷ បណ្តុះកូនឈើគ្រញ្ញូងបានចំនួន៥៩.០០០ដើម សម្រាប់ដាំលើផ្ទៃដីចំនួន៤០០ហិកតាបានគ្រប់ផែនការ ឈូសឆាយដីព្រៃបានចំនួន២១០ហិកតា និងស្ថានីយដាំឈើចំនួន១០ លើផ្ទៃដីចំនួន៣.៨៦៨ហិកតា ត្រូវធ្វើការថែទាំនិងការពារជាប្រចាំ។ ដោយឡែក ចម្ការឈើឆ្នាំទី១ឬឆ្នាំទី២ដែលទទួលរងការខូចខាតដោយភ្លើងឆេះកំពុងរៀបចំដាំបំពេញផែនការឡើងវិញ នៅតាមស្ថានីយដាំឈើមានក ភ្នំត្បូលេន ក្បាលឆាយ និងក្រសាំង

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន០៩មានសកម្មភាពឈូសឆាយដីព្រៃចំនួន ១១.១៩៥,៨៦ហិកតា និងដាំកូនឈើនិងកូនកៅស៊ូចំនួន ៣.៣៤៩,១៨ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៧៥៤.១៩៧ដើម កូនឈើបណ្តុះក្នុងឆ្នាំ២០១៣សរុបចំនួន២.៥៦៥.៨៤៧ដើម និងចែកចាយកូនឈើក្នុងឆ្នាំ២០១៣ សរុបចំនួន១២១.៣៣០ដើម

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ ៩ហិកតា ដែលមានទីតាំងនៅខេត្តកំពង់ធំកំពុងដំណើរការឈូសឆាយ

-តារដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានធ្វើផ្លូវមេចំនួន៥០គីឡូម៉ែត្រ ឈូសឆាយដីព្រៃចំនួន៤៣០គីឡូម៉ែត្រលើផែនការ២.៤០០ហិកតា ផលិតកូនឈើអាកាស្យាកូនចំនួន២លានកូន សាងសង់ផ្ទះចំនួន១២ខ្នង រោងជាងចំនួន១ខ្នង ការិយាល័យចំនួន១ខ្នង ឃ្លាំងចំនួន២ខ្នង អាងស្តុកទឹកចំនួន២ និងសាងសង់រោងចក្រកែច្នៃឈើ

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ខមភេនី លីមីធីត បានឈូសឆាយដីចំនួន ៨៥ហិកតាលើផែនការ៣៥០ហិកតា បណ្តុះកូនឈើចំនួន១០.០៧៦ដើម មាន៣ប្រភេទពីប្រទេសឡាវ សម្រាប់ដាំពិសោធន៍ និងបណ្តុះកូនអាកាស្យាហាយប្រីតចំនួន៦៥០.០០០ដើម សាងសង់អគារចំនួន២ខ្នង អាងស្តុកទឹកចំនួន២ និងបំពាក់ម៉ាស៊ីនភ្លើងចំនួន២គ្រឿង។

### ២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន០៧ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០៨ ដែលមានបរិមាណឈើចំនួន១៧.៨៨៨,៩៨៦ម$^{៣}$

-ពន្យារអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើចំនួន៦១,៣៥២ម$^{៣}$

-ផ្តល់គោលការណ៍នាំចេញជូនក្រុមហ៊ុនចំនួន០៣ ដែលមានបរិមាណឈើចំនួន២៥០.០៣៣តោន។

២.៥.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០៣ ស្មើនឹង១២៨សន្លឹក។

### ២.៦ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន ៧២០ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន២២៨,១៧០ម$^{៣}$ ឈើអារចំនួន២.៩៧៧,៧០២ម$^{៣}$ ឈើជ្រុងចំនួន១៤៤,៦៣២ម$^{៣}$ ឈើក្រាក់គ្រញូងចំនួន៥៣,៣៤៥ម$^{៣}$និង២.៤២៣គ.ក្រ កូនឈើចំនួន១.៣៦១ដើម ឈើជន្លង់ម្រេចចំនួន១.៨៦៧ដើម ឫស្សីចំនួន១៥២ដើម អុសចំនួន៤៥,៦០ស្ទែរ ផ្តៅចំនួន៦.០០០គ.ក្រ ជ័រទឹកចំនួន៥.០០០គ.ក្រ ពកធ្មង់ចំនួន១៣០គ.ក្រ គ្រាប់ស្លែងចំនួន៥.៣៥៩គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៣៦៩,២០គ.ក្រនិង១.៥៧០ក្បាល ស្បែកពស់ថ្លាន់ចំនួន០៣បន្ទះ រថយន្តចំនួន២៤៨គ្រឿង ត្រាក់ទ័រចំនួន១២គ្រឿង អេស្កាវ៉ាទ័រចំនួន០៣គ្រឿង ម៉ូតូចំនួន៧៨គ្រឿង ទូក-កាណូតចំនួន១១គ្រឿង គោយន្តចំនួន១៩គ្រឿង រទេះកង់ឡានចំនួន ២១គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន២២គ្រឿង ម៉ូទ័រចំនួន០៩គ្រឿង ឌីណាម៉ូចំនួន០១គ្រឿង តុឈូសច្រៀកឈើចំនួន០៩គ្រឿង រណារខ្សែចំនួន០៧គ្រឿង រណារយន្តចំនួន៣៧គ្រឿង និងសម្ភារផ្សេងៗទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន ១.១៥៣,៦៧០ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើកម្មសិទ្ធិ ចំនួន ១.៤៦២,៤៩៥ហិកតា និងដកហូតដីព្រៃដែលបានកាប់រានសរុបចំនួន១.៦៤៤,២៦០ហិកតា ។

## ៣ ផ្នែកជលផល

### ៣.១ អាជីវកម្មនេសាទ

៣.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១២-២០១៣ សរុបបានចំនួន៨.៥០០តោន ស្មើ៨៥%នៃផែនការ ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៧.៥០០តោន

-នេសាទត្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ សរុបបានចំនួន១៣០.០០០តោន ស្មើ៤៣,៣៣% នៃផែនការ ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤០.០០០តោន

-នេសាទត្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ សរុបបានចំនួន៥០.០០០តោន ស្មើ៣៣,៣៣% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៥.០០០តោន ។

៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

-អនុវត្តបានចំនួន៥១.០០០តោន ស្មើ៥៦,៦៧% នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន។

### ៣.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៤២.០០០តោន ស្មើ៥២,៥០% នៃផែនការ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣.០០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន១៥០.០០០ក្បាល ស្មើ៧៥% នៃផែនការ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៨.៨៣០ក្បាល

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួន៧០.០០០.០០០កូន ស្មើ៤៦,៦៧% នៃផែនការ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០.០០០កូន ។

### ៣.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ សរុបបានចំនួន៣៥.០០០តោន ស្មើ៣៥% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៥.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ សរុបបានចំនួន៤.៧០០តោន ស្មើ៧៨,៣៣% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

-ការផលិតទឹកត្រី សរុបបានចំនួន៣៨.០០០.០០០លីត្រ ស្មើ៦៣,៣៣% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០លីត្រ។

### ៣.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ សរុបបានចំនួន៦.៥០០តោន ស្មើ៣២,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន៣.០០០តោន ស្មើ៣០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០០តោន។

### ៣.៥ ការការពារប្រភពធនធានជលផល

-កំណត់ហេតុបទល្មើស សរុបចាប់ពីដើមឆ្នាំចំនួន ១.៤៦៨ករណី ដែលកើតមាននៅតំបន់ទឹកសាប ១.៤២៦ករណី និងតំបន់សមុទ្រ ៤២ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ៣៣៩ករណី គឺតំបន់ទឹកសាប ៣៣៩ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៣.៦ ការប្រមូលចំណូល

-ចំណូលពីវិស័យជលផល សរុបបានចំនួន១.៤០៤.៤៥៦.៦៩៧រៀល ស្មើ៤៧,៦៦% នៃផែនការ២.៩៤៧.០០០.០០០ រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.៤៦៨.២១០.១០៣រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៤.១ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ ក្របី និងពពែ ជំងឺសារទឹកចំនួន ២៣៨.៨២២ក្បាល ជំងឺអុតក្តាមចំនួន ១០.០២៥ ក្បាល និងជំងឺបូសខ្យល់ចំនួន១.៦០០ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៤៦.៩៥៣ក្បាល ជំងឺប៉េស្តចំនួន៧៩.៩៩៥ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៤២.៧១៦ក្បាល ជំងឺអុតក្តាមចំនួន៦០២ក្បាល ជំងឺអូហ្យេស្គីចំនួន១០.៨១៧ក្បាល ជំងឺរាគកូនជ្រូកចំនួន ១៣.២៤៤ក្បាល ជំងឺកញ្ជ្រឹលចំនួន៣២០ក្បាល ជំងឺជាតិដែកចំនួន៨.៥៦៥ក្បាល និងជំងឺផ្លូវដង្ហើមចំនួន៣៤០ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៩២.៥៨៦ក្បាល ជំងឺញូវកាសចំនួន១៩២.៩៤១ក្បាល ជំងឺប៉េស្តទាចំនួន៣៧.០០៣ក្បាល ជំងឺអាសន្នរោគចំនួន១២៦.៩០៧ក្បាល និងជំងឺហ្គុមបូរូចំនួន៣.២០០ក្បាល។

### ៤.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឱ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ៨.៧៩០សំណាក

-ផ្នែកសរីរវេគសាស្ត្រសរុបចំនួន ១២៤ក្បាល ។

### ៤.៣ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ៦៥ករណី មកពីបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺងាប់

-ក្នុងឆមាសទី១ ឆ្នាំ២០១៣នេះមានករណីផ្ទុះជំងឺផ្តាសាយបក្សីប្រភេទ H5N1 ចំនួន០៦ករណី គឺ០១ករណីនៅក្នុងភូមិស្មោ ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ ០១ករណីនៅក្នុងភូមិព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ០២ករណីនៅក្នុងភូមិក្បាលអូរ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់និងភូមិតាឡៃ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ០១ករណីនៅក្នុងភូមិស្រងែ ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត និង០១ករណីនៅក្នុងភូមិខ្នាថ្មី សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសរំសាយតំបន់ផ្ទុះជំងឺផ្តាសាយបក្សីចំនួន០៤កន្លែង នៅភូមិក្បាលអូរ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ នៅភូមិតាឡៃ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម នៅភូមិព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងនៅភូមិស្មោ ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ

-ត្រួតពិនិត្យការដឹកជញ្ជូនគោ ក្របីចំនួន៩៥ករណី ជ្រូកចំនួន៩១ករណី ស៊ុតចំនួន០៦ករណី មាន់ចំនួន០៤ករណី និងធ្វើការផាកពិន័យបានចំនួន២០ករណី ស្មើនឹង ៦៣.៥០០.០០០រៀល

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋនិងអាជីវករឱ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៤.៤ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ៤២៤ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៦-២០១១ (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I- ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៧០,៧១ | ១៤៥,៦១ | ៩៤,០០ |
| *សរុប I* | | *៣៦៧,៧០* | *៣៧០,៧១* | *១៤៥,៦១* | *៩៤,០០* |
| *II- ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ៨.៤៨៨,២៧ | ៤.៧១៨,៩៦ |
| ២ | ក្រុមហ៊ុន ស៊ីហ្វូរ៉ាប់ប៊ើលីមីធីត(រតនគីរី) | ៨៦៧,៩៤ | ៩៥៤,៨៩ | ៤០២,៩៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.០២០,៨៨ | ៩៥៥,៩៧ | ៣៨៦,៤៣ | ២៣១,២០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.១៩៨,០៨ | ៩១២,១១ | ៣៥០,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៤.៤៩៦,៦៥ | ២.០៨៣,៦៣ | ១.២៩៨,៤០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វូវីសសស់ (ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៤១ | ១.១៥៥,៨០ | ៩០០,១០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប(ពាមជាំង) | ២.២៤៣,២៦ | ១.១៥៧,៦៥ | ៤៩០,៩៨ | ៣១៧,៤០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៥៦០,៨៨ | ៣៥៧.០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | | ៦៩៦,១៧ | | |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៣៩៦,៧៥ | ១.៤៥៥,១៨ | ១.១៥៧,៤០ |
| *សរុប II* | | *២៥.៣៩០,៦៧* | *២៧.០៥៧,៥៤* | *១៥.៩៣៦,២៦* | *៩.៣៣០,៤៦* |
| សរុប I+II | | ២៥.៧៥៨,៣៧ | ២៧.៤២៨,២៥ | ១៦.០៨១,៨៧ | ៩.៤២៤,៤៦ |

### ៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ទទួលនិស្សិតចុះធ្វើកម្មសិក្សាសរសេរសារណាបទថ្នាក់បរិញ្ញាបត្រចំនួន០៣នាក់

-បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពីការដាំដុះនិងថែទាំកៅស៊ូ។

### ៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ត្រួតពិនិត្យថែទាំនិងការពារគ្រប់ឡូត៍ពិសោធន៍កូន

-ជំរឿនកូនកៅស៊ូងាប់ក្នុងឡូត៍ពិសោធន៍ IRAA10 សរុបប្រមាណ ៧.១៥៤ដើម

-ត្រួតពិនិត្យការបំបៅកូន CMS កូន CMSចំនួន៩ សរុបប្រមាណ ៧.១៥៤ដើម

-ដាំឡូត៍ពិសោធន៍កូន CMS (IRAA11) លើផ្ទៃដីសរុបចំនួន៦,៦៤ហិកតា

-បើកវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងច្បារពូជនិងថ្នាលបណ្តុះកូនកៅស៊ូបាន០១វគ្គ។

### ៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-ចំពោះប្រព័ន្ធចៀរជ័រ d4 ពូជ IRCA 230 ផ្តល់ទិន្នផលជ័រខ្ពស់ជាងគេនៅបច្ច័យ T1: S/2 d4 7d/7 ET 2,5% Pal 8/y បើប្រៀបធៀបទៅនឹងពូជនៃបច្ច័យផ្សេងទៀត

-ចំពោះការពិសោធន៍លើការបើកចៀរជុំវិញទំហំដើមខុសគ្នាបានបង្ហាញថាទំហំដើម៤៥ស.ម ទទួលទិន្នផលបានខ្ពស់ជាងទំហំដើមនៃបច្ច័យផ្សេងទៀត។

### ៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-ដាក់ជីចម្ការពិសោធន៍ជីលើកទី១

-សហប្រតិបត្តិការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kyushu ដើម្បីស្រាវជ្រាវអំពី Leaf photosynthesis ។

### ៥.៦ ការងារនៅស្ថានីយអនុវត្ត

-បំប៉ៅកូនកៅស៊ូនៅថ្នាលកូនប្លុក១១ ចំនួន២៨.០០០កូន

-រៀបចំភ្ជួរដីនិងខួងរណ្ដៅសម្រាប់ដាំកៅស៊ូឆ្នាំ២០១៣។

### ៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន១២៧ភាគសំណាក ដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រ

-ចុះបញ្ជិកាមន្ទីរពិសោធន៍យថាប្រភេទនៃក្រុមហ៊ុន ស៊ីហ្វូ រីសសស៍ ខេមបូឌា លីមីធីត ចម្ការកៅស៊ូស្នួល ដើម្បីទទួលស្គាល់ជាផ្លូវការនិងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១០៨ ជាមួយ IRA ដើម្បីពង្រឹងសមត្ថភាពលទ្ធផលតេស្តនិងសម្រាប់កិច្ចសន្យាកៅស៊ូ TSRs

-រៀបចំសំណាកធ្វើតេស្តមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៣៤

-ចុះបេសកកម្មត្រួតពិនិត្យតាមដានរោងចក្រកែច្នៃកៅស៊ូCSRនៃក្រុមហ៊ុន ស៊ីហ្វូ រ៉ាប់ប៊ើ លីមីធីត ចម្ការកៅស៊ូ រតនគិរី

-ទទួលនិស្សិតមហាវិទ្យាល័យកសិកម្មនៃសាកលវិទ្យាល័យស្វាយរៀងចំនួន៣១នាក់ ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ទ្រឹស្តីនិងការអនុវត្តជាក់ស្តែង។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន២.៥៣៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន១.៩៥៩ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៤៦៥ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៤.១៥៥ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន២៨៤ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៤៧៨ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

-រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣ បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីដាក់ឱ្យដំណើរការដេញថ្លៃជាសាធារណៈលើគម្រោងចំនួន០៨

-ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណើសុំគោលការណ៍ចំណាយថវិកាជំពូក២១ សម្រាប់ឆ្នាំ២០១៣ ចំនួន ១៩.៩៩៧.១១៧.០០០រៀល សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អគារបណ្ដុះបណ្ដាល និងរបងនៅតាមបណ្ដាកសិដ្ឋានផលិតពូជស្រូវ ស្ថានីយពិសោធន៍កសិកម្ម និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម

-ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណើសុំថវិកាបដិភាគចំនួន ១៤៣.៦៣១,៦៧ដុល្លារអាមេរិក សម្រាប់ចូលរួមចំណែកក្នុងការអនុវត្តគម្រោង Forest Restoration and Establishment of Forest Research Facilities ឆ្នាំទី២ (២០១៣) ក្រោមជំនួយហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋកូរ៉េ

-គណនីនៅតាមធនាគាររដ្ឋនិងធនាគារពាណិជ្ជនានាសរុបចំនួន ២៦គណនី (NBC: ៦, FTB: 11, ACLEDA: ៧, ANZ: 2)

-បានទទួលបង្កាន់ដៃប្រាក់កក់ធានាអនុវត្តកិច្ចសន្យាចំនួន ០៤ក្រុមហ៊ុន គឺក្រុមហ៊ុន HOLLEY ECO-INDUSTRIAL (CAMBODIA) CO.,LTD ក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន ក្រុមហ៊ុន កំពង់ស្ពឺស៊ូហ្គើរ និងក្រុមហ៊ុន ភ្នំពេញស៊ូហ្គើរ

-ប្រជុំពិភាក្សាកម្រិតជំនាញជាមួយនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើដំណើរការអនុវត្តប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចតាមការណែនាំថ្មីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន០៤ក្នុងចំណោម៦៦ក្រុមហ៊ុនបានបង់ថ្លៃសម្បទានតាមសេចក្តីជូនដំណឹងលេខ ៩៥៧៦/១១៧៨ កសក.សជណ.គហ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២

-រំលឹកទៅក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឱ្យអនុវត្តតាមសេចក្តីណែនាំថ្មី ស្តីពីការបង់ថ្លៃសម្បទាន $5/ha/1 year និងកើន ១% ជារៀងរាល់ឆ្នាំដោយគិតចាប់តាំងពីឆ្នាំទី៧តទៅ។

## ៨ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-សម្របសម្រួលរៀបចំបែបបទនិងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន២៦៨នាក់ នៅក្នុងប្រទេសចំនួន២៦

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំការអនុញ្ញាតជូន**ឯកឧត្តមរដ្ឋមន្ត្រី**អមដំណើរ**សម្តេចតេជោ**នាយករដ្ឋមន្ត្រីចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-រៀបចំលិខិតទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំគោលការណ៍អនុញ្ញាតធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន

-រៀបចំលិខិតទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់យោបល់ Reservation List ពាក់ព័ន្ធនឹងពិធីសារស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនផ្លូវការចំនួន២១ច្បាប់ និងស្នើសុំចាត់តំណាងស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមកិច្ចប្រជុំលើកទី៣៦ នៃក្រុមប្រឹក្សាទេសាភិបាលរបស់អង្គការ IFAD នៅប្រទេសអ៊ីតាលី

-ពិនិត្យខ្លឹមសារសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការវិស័យកសិកម្មកម្ពុជា-ឥណ្ឌូនេស៊ី

-ពិនិត្យនិងកែសម្រួលសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីផលិតកម្មតាមកិច្ចសន្យា Contract Farming ក្នុងក្របខ័ណ្ឌ ACMECS សម្រាប់ដាក់បញ្ចូលក្នុងកិច្ចប្រជុំកំពូល ACMECS លើកទី៥ នៅប្រទេសឡាវ

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ស្នើជួយអន្តរាគមន៍ទៅស្ថានឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្គីណេប្រចាំទីក្រុងបេកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីចាត់គណៈប្រតិភូឬតំណាងផ្លូវការមកពិភាក្សាការងារក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងសាធារណរដ្ឋហ្គីណេក្នុងការធ្វើពាណិជ្ជកម្មអង្ករនិងការបង្កើតគម្រោងផលិតកម្មស្រូវ

-រៀបចំលិខិតអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំអ្នកឯកទេសស្ម័គ្រចិត្តចំនួន២រូបពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េសម្រាប់បង្កើនគុណភាពអប់រំផ្នែកវេជ្ជសាស្ត្រសត្វនិងវិទ្យាសាស្ត្រសត្វ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មរយៈពេល១ឆ្នាំ

-រៀបចំលិខិតអន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំប័ណ្ណសម្គាល់និងស្លាកលេខ ONG នូវរថយន្តចំនួន១គ្រឿងជូនអង្គការ Wildlife Alliance និងបន្តអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការ HEKS អង្គការ POH KAO និងអង្គការ German Agro Action (GAA) ជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-បញ្ជូនមន្ត្រី០១រូបចូលរួមត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពនៃការអនុវត្តគម្រោង Wildlife Alliance ទស្សនកិច្ច និងពិនិត្យកម្មវិធីផ្តល់ជំនួយខ្នាតតូច (SGP) នៅខេត្តកោះកុង។

## ៩ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ធ្វើពិសោធន៍ចំនួន៤៣ប្រភេទ នៅ២៥៩កន្លែង ក្នុងនោះពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញចំនួន ១២៨កន្លែង

-ធ្វើអង្កេតចំនួន៤ប្រភេទដោយធ្វើសម្ភាសន៍កសិករចំនួន៥.៩០០គ្រួសារ

-រៀបចំនិងបោះពុម្ពសៀវភៅស្មៅចង្រៃនៃដំណាំស្រូវនៅអាស៊ីចំនួន១.៥០០ច្បាប់ និងបានធ្វើការបែងចែកសៀវភៅ ឯកសារនានាចំនួន៣.៥៧០ច្បាប់ និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន៥.៤០០ច្បាប់ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករ

-បន្តអភិរក្សពូជដំណាំចំនួន៣០ប្រភេទ ក្នុងនោះស្រូវចំនួន៦.១១៧បញ្ជី/សំណាក និងដំណាំផ្សេងៗចំនួន២៩ ប្រភេទ ស្មើនឹង៩៦៥បញ្ជី/សំណាក និងធ្វើយុវកម្មសរុបចំនួន១.០០៥បញ្ជី/សំណាក

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៩៦.៨១៥នាក់ គិតជាមធ្យមប្រមាណ៥៣៨នាក់ក្នុងមួយថ្ងៃ ក្នុងនោះប្រទេសកម្ពុជាចំនួន ៦៥% សហរដ្ឋអាមេរិកចំនួន១២% អូស្ត្រាលីចំនួន ៦% ជប៉ុនចំនួន៥% វៀតណាមចំនួន៤% និងប្រទេសផ្សេងៗទៀត(៩៤ ប្រទេស) ចំនួន៨%

-បើកវគ្គបណ្តុះបណ្តាលកសិករចំនួន៧វគ្គ ដែលមានអ្នកចូលរួមចំនួន២៥៧នាក់ បានចែកពូជស្រូវក្នុងចំណោម ពូជស្រូវ១០ពូជក្នុងមួយគ្រួសារចំនួន៥គីឡូក្រាមជូនដល់កសិករចំនួន១៦៦គ្រួសារ នៅក្នុងខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ

-បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន៥វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន១១៧នាក់

-ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន៨លើក ដែលមានអ្នកចូលរួមចំនួន៩នាក់ និងក្រៅប្រទេសចំនួន១៤លើក ដែលមានអ្នកចូលរួមចំនួន១៩នាក់។

## ១០ ផ្នែកការងារបញ្ជ្រាបយេនឌ័រ

-បើកវគ្គបណ្តុះបណ្តាលស្តីពីការងារបញ្ជ្រាបយេនឌ័រជូនដល់ភ្នាក់ងារផ្សព្វផ្សាយសុខភាពសត្វភូមិបានចំនួន៣ខេត្ត គឺខេត្តក្រចេះចំនួន ៥០នាក់ ក្នុងនោះស្ត្រីចំនួន ២៣នាក់ ខេត្តកំពង់ឆ្នាំងចំនួន៥០នាក់ ក្នុងនោះស្ត្រីចំនួន ១០នាក់ និងខេត្តកំពង់ចាមចំនួន ៥០នាក់ ក្នុងនោះស្ត្រី ៨នាក់។ ក្រៅពីនេះការបញ្ជ្រាបសកម្មភាពយេនឌ័រតាមរយៈគម្រោងនានាក៏កំពុងត្រូវបានយកចិត្តទុកដាក់។

## ១១ ផ្នែកការងារសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា

-សមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជាចំនួន៤២សាខា ដោយមានមន្ត្រីរាជការនិងនិវត្តជនចូលជាសមាជិកចំនួន ៦.៣៤៦នាក់ ក្នុងចំនួនក្របខ័ណ្ឌមន្ត្រីរាជការសរុបចំនួន៦.៧៥៦នាក់

-សមាជិក សមាជិកាចំនួន៣៦នាក់ និងគ្រួសារចំនួន០៦នាក់ បានទទួលមរណភាព ក្នុងនោះសមាគមមិត្តបុគ្គលិក

កសិកម្មកម្ពុជាបានឧបត្ថម្ភនូវថវិកាដល់សពសមាជិកម្នាក់ៗចំនួន ៦.០០០.០០០រៀល និងសពគ្រួសារចំនួន ៣.០០០.០០០ រៀល សរុបចំណាយ ២៣៤.០០០.០០០រៀល។ ដោយឡែក ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា និងលោកជំទាវ ដែលបានឧបត្ថម្ភនូវអង្ករសប្បុរសធម៌ដល់សពសមាជិកម្នាក់ៗចំនួន១០០គីឡូក្រាម សរុបចំនួន៣.៦០០គីឡូក្រាម។

## ១២ សាលាជាតិកសិកម្មព្រែកលៀប

### ១២.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៩០នាក់(ស្រី៥០៩នាក់)ក្នុងនោះ÷

•និស្សិតអាហារូបករណ៍ចំនួន១.២០៦នាក់ ក្នុងនោះស្រី៤៣៨នាក់ ÷

-ថ្នាក់បរិញ្ញា *៩៦៣*នាក់ (ស្រី ៣៤៧នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *២៤៣*នាក់ (ស្រី ៩១នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

•និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៥៤*នាក់ (ស្រី ២៤នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *៤២*នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

•និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៨៨នាក់ ក្នុងនោះ ស្រី៤៤នាក់ ÷

-ថ្នាក់បរិញ្ញា *១៤៨*នាក់ (ស្រី ៣៧នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង *៤០*នាក់ (ស្រី ០៧នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

### ១២.២ ការងារផ្សព្វផ្សាយ

-បើកវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់និងចិញ្ចឹមជ្រូក ដែលមានសិក្ខាកាមចូលរួមចំនួន៨៤នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីការផលិតមេផ្សិតនិងបណ្តុះផ្សិត ដែលមានសិក្ខាកាមចូលរួមចំនួន១០៩នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីជំងឺសត្វនិងការការពារ ដែលមានសិក្ខាកាមចូលរួមចំនួន០៦នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីដំណាំកៅស៊ូនិងដំណាំហូបផ្លែ ដែលមានសិក្ខាកាមចូលរួមចំនួន០៧នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីជំងឺនិងព្យាបាលសត្វ ដែលមានសិក្ខាកាមចូលរួមចំនួន០៧នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រី កង្កែប អន្ទង់ ដែលមានសិក្ខាកាមចូលរួមចំនួន១២នាក់។

### ១២.៣ ការងារផលិតកម្មនិងស្រាវជ្រាវ

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្លាន ស្លាកន្ទុយកំប្រុក

-ធ្វើការពិសោធន៍ពូជពោតបានចំនួន៤ពូជ÷ ពូជលេខ១ដាំបានចំនួន៣២០គុម្ព ពូជលេខ២ដាំបានចំនួន៣២០ គុម្ព ពូជលេខ៣ដាំបានចំនួន៣២០គុម្ព ពូជលេខ៤(កសិករ)ដាំបានចំនួន៣២០គុម្ព និងពិសោធន៍ដំណាំស្ពៃតឿចំនួន ០២ពូជ គឺពូជម៉ាឡេស៊ីនិងពូជថៃចំនួន២៤កូនស្រែ។

**១៣ សាលាជាតិកសិកម្មកំពង់ចាម**

**១៣.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់) ក្នុងនោះ ÷**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

**១៣.២ ការងារពិសោធន៍ស្រាវជ្រាវ**

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

**១៣.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាកសិកម្ម**

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

**១៤ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៥៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍

ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវនៅដើមរដូវវស្សាឆ្នាំ២០១៣នេះ អំណោយផលទឹកភ្លៀងនៅមិនទាន់រាយប៉ាយគ្រប់ទីកន្លែង ហើយដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សាមានសភាពយឺតជាងឆ្នាំមុន បើប្រៀបធៀបរយៈពេលដូចគ្នា។ ទោះជាយ៉ាងនេះក្តី ប្រជាកសិករកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប-ព្រោះ និងដក-ស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។

## IV- ទិសដៅ

-ជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៣ ជាពិសេសស្រូវស្រាលដើមរដូវ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឲ្យបានប្រវែង ១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបនៅរាជធានី ខេត្តឲ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឲ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៣

រដ្ឋមន្ត្រី

ចាន់ សារុន